


**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**
លេខ:...០៤១.........សជណ.សក.ព១

## សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការលេខទូរសព្ទ HOTLINE "1275" របស់មណ្ឌលប្រឹក្សាយោបល់លើសេវាសាធារណៈ

ក្រសួងសាធារណការ និងដឹកជញ្ជូន មានកិត្តិយស សូមជម្រាបជូនដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឱ្យបានជ្រាបថា៖ ក្រសួងបានដាក់ឱ្យដំណើរការជាផ្លូវការលេខទូរសព្ទ HOTLINE ៤ខ្ទង់ **"1275"** សម្រាប់បងប្អូនប្រជាពលរដ្ឋអាចធ្វើការហៅចូលទំនាក់ទំនងរៀងរាល់ម៉ោងធ្វើការ ក្នុងការប្រឹក្សាយោបល់ពាក់ព័ន្ធនឹងវិស័យសាធារណការ និងដឹកជញ្ជូន តាមរយៈមណ្ឌលប្រឹក្សាយោបល់លើសេវាសាធារណៈ។

ប្រព័ន្ធទូរសព្ទនេះ នឹងជួយសម្រួលដល់បងប្អូនប្រជាពលរដ្ឋក្នុងការហៅចូលដោយឥតគិតថ្លៃ ដើម្បីសាកសួរព័ត៌មាន ដោះស្រាយបញ្ហា សុំជំនួយបច្ចេកទេស និងប្រឹក្សាយោបល់ឱ្យកាន់តែមានប្រសិទ្ធភាពជុំវិញសេវាសាធារណៈ និងប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ ការប្រឡងយកបណ្ណបើកបរ ត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ(ឆៀក) ការផ្ទេរកម្មសិទ្ធិយានជំនិះ ចុះបញ្ជីអាជីវកម្ម កម្មវិធីយល់ដឹងអំពីទ្រឹស្តីនៃការបើកបរ(Cambodia Driving Rules) និងកម្មវិធីថែទាំផ្លូវ(ROAD CARE Mobile App) ជាដើម។ល។

អាស្រ័យហេតុនេះ សូមបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ.................ខែ..........ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី.........ខែ..........ឆ្នាំ២០២០